ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ ៣៨៦ សជណ

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩

# ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ជំរាបមក**

## ឯកឧត្តម អភិបាលរាជធានីភ្នំពេញ

## ឯកឧត្តម អភិបាលគ្រប់ខេត្ត

**កម្មវត្ថុ** : ស្តីពីការណែនាំបន្ថែមអំពីការឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុងប្រឹក្សាស្រុក ចំពោះមន្ត្រីដែលមានមុខតំណែងជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**យោង** : - លិខិតជូនដំណឹងលេខ ២៣៨ សជណ ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ។

- សេចក្តីសម្រេចលេខ ១០៥/០០១/២០០៩ កបធ.ច ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបមកឯកឧត្តមថា : កន្លងក្រសួងមហាផ្ទៃ បានចេញសេចក្តីជូនដំណឹង ដូចមានយោងខាងលើ ដើម្បីណែនាំអំពីបែបបទ និងនីតិវិធីមួយចំនួន ទាក់ទិននឹងការឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុងប្រឹក្សាស្រុក ចំពោះមន្ត្រីដែលមានមុខតំណែងជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ តាមស្មារតីលិខិតជូនដំណឹងនេះ សំរាប់មន្ត្រីរាជការស្ថិតក្នុងមុខតំណែងជាអភិបាល អភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវដាក់ពាក្យសុំឈប់ពីមុខតំណែង ដើម្បីទៅឈរឈ្មោះជាបេក្ខជនក្រុមប្រឹក្សា ។

ប៉ុន្តែអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដូចមានយោងខាងលើ មិនតម្រូវឱ្យសាមីខ្លួនលាឈប់ពីមុខតំណែងភ្លាមនោះទេ ។ ប្រសិនបើមន្ត្រីរាជការ ដែលមានបំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា សាមីខ្លួនត្រូវតែបំពេញលក្ខខណ្ឌដែលមានចែងក្នុងបទបញ្ញត្តិនៃមាត្រា **១៨** នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

ទាក់ទិននឹងបញ្ហាខាងលើនេះ ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវតាមបែបបទ និងនីតិវិធី សំរាប់មន្ត្រីរាជការដែលមានបំណងចង់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានោះ ក្រសួងមហាផ្ទៃ សូមធ្វើការជូនដំណឹងបន្ថែម ដូចតទៅ :

១. ទាំងមន្ត្រីរាជការស៊ីវិល ទាំងយោធា និងនគរបាលជាតិ ដែលកំពុងកាន់មុខតំណែងក្នុងរចនាសម្ព័ន្ធក្រសួងមហាផ្ទៃ ហើយដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់សំរាកពិសេសយ៉ាងតិចប្រាំពីរ (០៧) ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។ ការដាក់ពាក្យសុំច្បាប់ឈប់សំរាកពិសេស មានន័យថា ដាក់ពាក្យសុំច្បាប់សម្រាកពីការងារតែប៉ុណ្ណោះ មិនមានន័យថា ដាក់ពាក្យសុំលាលែងពីមុខងារ ឬពីមុខតំណែងឡើយ ។ ដូចនេះ មន្ត្រីរាជការ ដែលត្រូវឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវសុំការអនុញ្ញាតអវត្តមានពីការងារក្នុងរយៈពេលដូចបានកំណត់ខាងលើ ទៅតាមបែបបទ និងនីតិវិធីដែលបានកំណត់

២. ប្រសិនបើសាមីខ្លួនជាប់ឆ្នោតហើយមានបំណងចង់បំរើការងារជាសមាជិកក្រុមប្រឹក្សានោះ សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមមករដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬប្រធានស្ថាប័នសាមី ដើម្បីទៅបម្រើការងារក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា ។ ក្នុងរយៈពេល នៃអាណត្តិនេះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬឋានន្តរសក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ទៀតផង ។

៣. ចំពោះមន្ត្រីរាជការ ដែលទៅបំរើការងារជាសមាជិកក្រុមប្រឹក្សា នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនត្រូវធ្វើពាក្យស្នើសុំចូលបំរើការងារវិញ នៅក្រសួង ឬស្ថាប័នដើមរបស់ខ្លួន។ ការត្រឡប់មកបំរើការងារវិញ សាមីខ្លួននឹងអាចបានទទួលមុខងារ ឬមុខតំណែងដើមរបស់ខ្លួនវិញបាននោះ គឺអាស្រ័យដោយក្រសួង ឬស្ថាប័នជាអ្នកសម្រេច មិនមែនសាមីខ្លួនអាចទទួលមុខងារ ឬមុខតំណែងដើមរបស់ខ្លួនវិញ ជាស្វ័យប្រវត្តិនោះទេ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមជ្រាប និង ចាត់ចែងអនុវត្តតាមការគួរ ។

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**នាយឧត្តមសេនីយ៍ ឯម_សំអាន**

**<u>ចម្លងជូន</u>**

- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*(ដើម្បីជូនជ្រាប)*

-*ឯកសារ កាលប្បវត្តិ*